**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ : ០៩ អយក.សរណ

# សារាចរណែនាំ
# ស្តីពី
# របបនៃការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់បុគ្គលិកអប់រំ

ដើម្បីអនុវត្តអនុក្រឹត្យលេខ២១៧ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ស្តីពីរបបស្តីពីការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងធានានិរន្តរភាពការងារគ្រប់គ្រង និងដំណើការងារក្នុងអង្គភាពនានាក្នុងវិស័យអប់រំ យុវជន និងកីឡា ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការណែនាំដូចខាងក្រោម៖

**១. របបនៃការសុំច្បាប់**

របបនៃការសុំច្បាប់របស់បុគ្គលិកអប់រំចែកចេញជា៥ប្រភេទដូចខាងក្រោម៖

**១.១ ច្បាប់ឈប់រយៈពេលខ្លី** សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើមូលហេតុពិតប្រាកដដូចជា រៀបអាពាហ៍ពិពាហ៍ ការព្យាបាលជំងឺ ការថែទាំអ្នកជំងឺ ការចូលរួមមរណទុក្ខជាដើម។ បុគ្គលិកអប់រំមានសិទ្ធិសុំច្បាប់ឈប់សម្រាករយៈពេលខ្លីសរុបចំនួន១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការក្នុង១មួយឆ្នាំសិក្សាជាកំហិត។ ការសុំច្បាប់នេះអាចសុំមួយលើក ឬ ច្រើនលើកបាន។

**១.១.១ ការឈប់រយៈពេលខ្លីចាប់ពី ១(មួយ)ថ្ងៃ ដល់ ៥(ប្រាំ)ថ្ងៃ ៖**

- ចំពោះប្រធានអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួង ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង
- ចំពោះបុគ្គលិកអប់រំដែលបម្រើការនៅអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួង ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានអង្គភាពដែលគ្រប់គ្រងដោយផ្ទាល់
- ចំពោះប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយជូនដំណឹងមកក្រសួង
- ចំពោះអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំបម្រើការនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ចំពោះអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បុគ្គលិកអប់រំបម្រើការនៅក្រោមឱវាទរបស់ខ្លួន គណៈគ្រប់គ្រង និងបុគ្គលិកអប់រំគ្រឹះស្ថានសិក្សា



អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ៤២៧ ៣៥៦ / ២១៧ ២៥៣ / ៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣)២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ

- បុគ្គលិកអប់រំដែលបម្រើការនៅតាមគ្រឹះស្ថានសិក្សាដែលសុំច្បាប់ឈប់សម្រាកពី១(មួយ)ថ្ងៃ ដល់២(ពីរ)ថ្ងៃ ត្រូវមានការអនុញ្ញាតយល់ព្រមពីគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លើសពីនេះត្រូវមានការអនុញ្ញាតពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

**១.១.២ ការឈប់រយៈពេលខ្លីចាប់ពី ៦(ប្រាំមួយ)ថ្ងៃ ដល់១៥(ដប់ប្រាំ)ថ្ងៃ៖**

- ចំពោះប្រធានអង្គភាព និងបុគ្គលិកអប់រំដែលបម្រើការនៅក្រោមឱវាទទីស្ដីការក្រសួង ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង
- ចំពោះប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ឈប់ពីថ្នាក់ដឹកនាំក្រសួងតាមរយៈអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ចំពោះអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំបម្រើការនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ចំពោះអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បុគ្គលិកអប់រំបម្រើការនៅក្រោមឱវាទរបស់ខ្លួន គណៈគ្រប់គ្រង និងបុគ្គលិកអប់រំបម្រើការនៅគ្រឹះស្ថានសិក្សា ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

**១.២ ច្បាប់ឈប់សម្រាកលំហែមាតុភាព** សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើសិទ្ធិរបស់បុគ្គលិកអប់រំជាស្ត្រីមុន និង/ឬ ក្រោយពេលសម្រាលកូន។

- បុគ្គលិកអប់រំជាស្ត្រីមានសិទ្ធិសុំច្បាប់ឈប់សម្រាករយៈពេល៣ខែមុន និង/ឬក្រោយពេលសម្រាលកូន
- ចំពោះគ្រឹះស្ថានឧត្តមសិក្សា ប្រធានអង្គភាពនានា និងបុគ្គលិកអប់រំដែលបម្រើការនៅក្រោមឱវាទទីស្ដីការក្រសួង ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង
- ចំពោះប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង តាមរយៈអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ចំពោះអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំបម្រើការនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ចំពោះអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បុគ្គលិកអប់រំបម្រើការនៅក្រោមឱវាទរបស់ខ្លួន គណៈគ្រប់គ្រង និងបុគ្គលិកអប់រំបម្រើការនៅគ្រឹះស្ថានសិក្សា ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

**១.៣ ច្បាប់ឈប់សម្រាកព្យាបាលជំងឺ** សំដៅដល់ការអនុញ្ញាតឱ្យឈប់ចំពោះបុគ្គលិកអប់រំដែលមានជំងឺត្រូវការរយៈពេលឈប់សម្រាកព្យាបាលតាមវេជ្ជបញ្ជានៃគ្រូពេទ្យមានសមត្ថកិច្ច។

- ការសុំច្បាប់សម្រាកព្យាបាលជំងឺអាចមានរយៈពេលពី១ខែទៅ៣ខែក្នុងមួយលើកៗ។ រាល់ការសុំច្បាប់នេះមានរយៈពេលត្រឹមតែ១២ខែតែប៉ុណ្ណោះក្នុងអំឡុងពេលបម្រើការងារជាមន្ត្រីរាជការ។ ការសុំច្បាប់នេះត្រូវមានលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ចជាកំហិត
- បុគ្គលិកអប់រំដែលស្ថិតនៅក្រៅក្របខ័ណ្ឌដើមតិចជាង ឬ ស្មើនឹង៦ខែ ត្រូវសុំច្បាប់ឈប់សម្រាកព្យាបាលជំងឺនៅក្រសួងអប់រំ យុវជន និងកីឡា។ ក៏ប៉ុន្តែក្នុងករណីស្ថិតនៅក្រៅក្របខ័ណ្ឌដើមលើសពី៦ខែឡើងទៅ បុគ្គលិកអប់រំនោះត្រូវសុំច្បាប់ឈប់សម្រាកព្យាបាលជំងឺនៅក្រសួង ស្ថាប័នដែលសាមីជនកំពុងបម្រើការងារថ្មីនោះ
- បុគ្គលិកអប់រំដែលកំពុងស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតិចជាង ឬ ស្មើនឹង៦ខែ អាចមានសិទ្ធិសុំច្បាប់ឈប់សម្រាកព្យាបាលជំងឺបាន បុគ្គលិកអប់រំទាំងឡាយណាដែលកំពុងស្ថិតក្នុងភាពទំនេរគ្មានបៀវត្សលើសពី៦ខែឡើងទៅមិនមានសិទ្ធិសុំច្បាប់ព្យាបាលជំងឺទេ
- បុគ្គលិកអប់រំដែលទទួលបានច្បាប់ឈប់សម្រាកព្យាបាលជំងឺរយៈពេល១២ខែ ហើយនៅតែពុំអាចមកបម្រើការងារវិញបាន ត្រូវដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិក្នុងរយៈពេលមិនឱ្យលើស៦ខែ ហើយប្រសិនបើជំងឺនោះនៅតែព្យាបាលមិនជាទៀត បុគ្គលិកអប់រំរូបនោះត្រូវដាក់ឱ្យបាត់សម្បទាវិជ្ជាជីវៈ ឬ ដាក់ឱ្យចូលនិវត្តន៍តាមករណីនីមួយៗដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បុគ្គលិកអប់រំដែលមានជំងឺ ឬ គ្រោះថ្នាក់ដោយសារការបំពេញការងារ ឬ បំពេញបេសកកម្មដោយមានលិខិតបញ្ជាបេសកកម្ម និងលិខិតបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ច ត្រូវទទួលបានបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំដូចពេលបម្រើការងារដែរ។

**១.៣.១ ច្បាប់ឈប់សម្រាកព្យាបាលជំងឺតិចជាង ឬស្មើ ៣ខែ**

- ចំពោះប្រធានអង្គភាព និងបុគ្គលិកអប់រំដែលបំរើការនៅក្រោមឱវាទទីស្តីការក្រសួងត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង
- ចំពោះប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង តាមរយៈអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ចំពោះអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំយុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំបម្រើការនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្ត

- ចំពោះអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បុគ្គលិកអប់រំបម្រើការនៅក្រោមឱវាទរបស់ខ្លួន គណៈគ្រប់គ្រង និងបុគ្គលិកអប់រំបម្រើការនៅគ្រឹះស្ថានសិក្សា ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

**១.៣.២ ច្បាប់ឈប់សម្រាកព្យាបាលជំងឺលើកទី២** រាល់ច្បាប់ព្យាបាលជំងឺបន្ទាប់ទៀតលើសពី៣ (បី)ខែត្រូវមានការអនុញ្ញាតឈប់ពីថ្នាក់ដឹកនាំក្រសួង។

**១.៤ ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន** សំដៅដល់ការអនុញ្ញាតឱ្យឈប់ចំពោះបុគ្គលិកអប់រំដែលត្រូវការពេលវេលាដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួនឬគ្រួសារ។

- ការសុំច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួនដើម្បីការពារផលប្រយោជន៍ផ្ទាល់ខ្លួននិងគ្រួសារមានរយៈពេលមួយលើកមិនឱ្យតិចជាងរយៈពេល១(មួយ)ខែ ហើយការសុំច្បាប់នេះសរុបមិនឱ្យលើសរយៈពេល៣(បី)ខែក្នុងអំឡុងពេលបម្រើការងារជាមន្ត្រីរាជការជាកំហិត។ ក្នុងអំឡុងពេលឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន បុគ្គលិកអប់រំរូបនោះមានសិទ្ធិទទួលបានបៀវត្សមូលដ្ឋានព្រមទាំងប្រាក់បន្ទាប់បន្សំនៃបៀវត្សចំនួនពាក់កណ្តាល។
- រាល់ការសុំច្បាប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួនត្រូវមានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួង។ ការសុំច្បាប់នេះអាចសុំមួយលើក ឬ ច្រើនលើកបាន។ ក្នុងករណីពិនិត្យឃើញថាការសុំច្បាប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន អនុវត្តមិនត្រឹមត្រូវដូចការអះអាងទេនោះ ក្រសួងនឹងកោះអញ្ជើញបុគ្គលិកអប់រំរូបនោះចូលមកបម្រើការងារវិញជាបន្ទាន់។

**១.៥ ច្បាប់ឈប់ប្រចាំឆ្នាំ** សំដៅដល់ការអនុញ្ញាតឱ្យឈប់ដោយផ្អែកលើសិទ្ធិរបស់បុគ្គលិកអប់រំបន្ទាប់ពីបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ។

- បុគ្គលិកអប់រំដែលបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមានសិទ្ធិសុំច្បាប់ឈប់សម្រាកប្រចឆ្នាំចំនួន១៥ថ្ងៃនៃថ្ងៃធ្វើការក្នុងមួយឆ្នាំសិក្សា។ ការសុំច្បាប់នេះអាចសុំឈប់មួយលើកឬច្រើនលើក
- រយៈពេលឈប់សម្រាកប្រចាំឆ្នាំចំនួន១៥ថ្ងៃនៃឆ្នាំទី១ឬចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំទី១ដែលនៅសល់ បុគ្គលិកអប់រំអាចសុំច្បាប់ឈប់ចំនួនថ្ងៃនៅសល់បូកនឹងចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំទី២ចូលគ្នានៅឆ្នាំទី២បាន
- រយៈពេលឈប់សម្រាកប្រចាំឆ្នាំនេះ ត្រូវកាត់បន្ថយទៅតាមចំនួនសមាមាត្រចំពោះបុគ្គលិកអប់រំណាដែលបានទទួលការអនុញ្ញាតច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន ឬ ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ឬ ច្បាប់ឈប់សម្រាកស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- ចំពោះបុគ្គលិកអប់រំដែលបំរើការនៅអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួង ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង

- ចំពោះប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីថ្នាក់ដឹកនាំក្រសួង តាមរយៈអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ចំពោះអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំបម្រើការនៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ចំពោះអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំបម្រើការនៅក្រោមឱវាទរបស់ខ្លួន ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- ចំពោះបុគ្គលិកអប់រំដែលបម្រើការនៅតាមគ្រឹះស្ថានសិក្សា ត្រូវសុំច្បាប់ឈប់សម្រាករបស់ខ្លួនឱ្យចំពេលវិស្សមកាល ហើយការសុំឈប់នេះ ត្រូវមានការអនុញ្ញាតយល់ព្រមឱ្យឈប់ពីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- មន្ត្រីទទួលបន្ទុកគ្រប់គ្រងការងារបុគ្គលិកនៃអង្គភាពនីមួយៗ នៅក្នុងគ្រប់ឋានានុក្រមគ្រប់គ្រងវិស័យអប់រំ យុវជន និងកីឡា (ថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខ័ណ្ឌ និងថ្នាក់សាលារៀន) ត្រូវរៀបចំបញ្ជីផែនការឈប់ប្រចាំឆ្នាំរបស់បុគ្គលិកក្រោមឱវាទរបស់ខ្លួនឱ្យបានសមស្របដើម្បីធានានិរន្តភាពការងាររបស់អង្គភាពប្រព្រឹត្តទៅជាធម្មតាដោយគ្មានផលប៉ះពាល់អ្វីទាំងអស់។

## ២. វិធានរួមនៃច្បាប់ឈប់សម្រាកគ្រប់ប្រភេទ

- រាល់ច្បាប់ឈប់សម្រាកគ្រប់ប្រភេទដែលបានអនុញ្ញាតរួចហើយត្រូវចម្លងជូននាយកដ្ឋានបុគ្គលិកនៃក្រសួងអប់រំ យុវជន និងកីឡា
- ចំពោះការឈប់សម្រាកប្រចាំឆ្នាំ ការឈប់សម្រាករយៈពេលខ្លី និងការឈប់សម្រាកដោយមានកិច្ចផ្ទាល់ខ្លួន ប្រធានអង្គភាពនីមួយៗត្រូវធានានិរន្តរភាពការងាររបស់អង្គភាពខ្លួនប្រព្រឹត្តទៅជាធម្មតា
- រាល់ពាក្យស្នើសុំច្បាប់ឈប់គ្រប់ប្រភេទត្រូវដាក់ជូនអង្គភាព ឬ ក្រសួង តាមឋានានុក្រមនៃបុគ្គលិកអប់រំមានសមត្ថកិច្ច។ រាល់លិខិតអនុញ្ញាតឱ្យឈប់ ត្រូវចុះកាលបរិច្ឆេទនៃការចាប់ផ្តើមឈប់ និងការចូលបម្រើការងារវិញ
- បុគ្គលិកអប់រំដែលទទួលបានការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទ ត្រូវស្ថិតក្នុងភាពផ្តាច់ចេញពីការងាររហូតដល់ថ្ងៃចូលមប្រើការងារវិញ។ ក៏ប៉ុន្តែក្នុងករណីចាំបាច់ ប្រធានអង្គភាព ឬ ក្រសួងមានសិទ្ធិអញ្ជើញបុគ្គលិកអប់រំដែលបានទទួលការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទឱ្យចូលបម្រើការងារវិញឱ្យបានច្បាស់លាស់

- បុគ្គលិកអប់រំដែលទទួលបានការអនុញ្ញាតច្បាប់ឈប់ប្រចាំឆ្នាំ ច្បាប់ឈប់រយៈពេលខ្លី ច្បាប់ឈប់សម្រាកលំហែមាតុភាព ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ត្រូវទទួលបានបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សដូចពេលកំពុងបំពេញការងារដែរ
- បុគ្គលិកអប់រំជាស្ត្រីមានបុត្រទើបសម្រាលដែលអាយុក្រោម១ឆ្នាំមានសិទ្ធិចេញពីធ្វើការ១(មួយ)ម៉ោងមុនពេលកំណត់ក្នុងមួយថ្ងៃ។ រយៈពេល១ម៉ោងនេះអាចចែកចេញជាពីរបានគឺពេលព្រឹក៣០(សាមសិប)នាទី និងពេលរសៀល៣០(សាមសិប)នាទី
- បុគ្គលិកអប់រំដែលឈប់លើសរយៈពេលនៃការអនុញ្ញាតឱ្យឈប់ ត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ រយៈពេលដែលឈប់លើសនេះត្រូវបានលើកលែងប្រសិនបើបណ្តាលមកពីជំងឺ ឬ ប្រធានស័ក្តិ ឬ គ្រោះថ្នាក់ផ្សេងៗ។ ក្នុងករណីនេះ បុគ្គលិកអប់រំសាមីត្រូវជូនដំណឹងជាបន្ទាន់ដល់អង្គភាព ឬ ក្រសួងដោយបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬ ពីគ្រូពេទ្យមានសមត្ថកិច្ច ហើយអាចសុំច្បាប់ឈប់រយៈពេលខ្លីបន្ត ឬ សុំច្បាប់ឈប់ប្រភេទផ្សេងក៏បាន។

ទទួលបានសារាចរណែនាំនេះ ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា លោក លោកស្រីប្រធានមន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្ត លោក លោកស្រីប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ លោកនាយក លោកស្រីនាយិកានៃគ្រឹះស្ថានសិក្សា និងអង្គភាពពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

អ៊ឹម សិទ្ធី

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- គ្រប់មន្ទីរ អ.យ.ក. រាជធានី ខេត្ត "ដើម្បីអនុវត្ត"
- កាលប្បវត្ត-ឯកសារ នា.នីតិកម្ម